# DE INTERNATIONAL

## INFORMATION FOR PARENTS OF INTERNATIONAL STUDENTS IN PRIMARY SCHOOLS

ច្បាប់របស់ប្រទេសអូស្ត្រាលីលើកកម្ពស់ការអប់រំប្រកបដោយគុណភាព និងការការពារអ្នកប្រើប្រាស់សម្រាប់សិស្សបរទេស។ ច្បាប់ទាំងនេះត្រូវបានគេស្គាល់ថាជាក្របខ័ណ្ឌ ESOS ហើយរួមមានច្បាប់សេវាកម្មអប់រំសម្រាប់និស្សិតបរទេស (ESOS) ឆ្នាំ2000 និងក្រមថ្នាក់ជាតិ។

សម្រាប់សេចក្តីសង្ខេបនៃក្របខ័ណ្ឌ ESOS សូមចូលទៅកាន់គេហទំព័រ៖

https://internationaleducation.gov.au/Regulatory-Information/Pages/Regulatoryinformation.aspx

សម្រាប់ព័ត៌មានអំពីលក្ខខណ្ឌតម្រូវទិដ្ឋាការសិស្ស សូមមើលគេហទំព័ររបស់ក្រសួងកិច្ចការផ្ទៃក្នុង (Department of Home Affairs)៖ http://www.homeaffairs.gov.au

សូមទាក់ទងអ្នកសម្របសម្រួលនិស្សិតអន្តរជាតិនៅសាលារៀនរបស់កូនអ្នកប្រសិនបើអ្នកមានកង្វល់ ឬសំណួរណាមួយអំពីសាលារៀន បញ្ហាផ្ទាល់ខ្លួន ឬបញ្ហាផ្សេងៗទៀត។ អ្នកសម្របសម្រួលនិស្សិតអន្តរជាតិនឹងជួយអ្នក ឬបញ្ជូនអ្នកទៅកាន់បុគ្គលិកដែលសមស្រប។

បទប្បញ្ញត្តិនានាខាងក្រោមអនុវត្តចំពោះការសិក្សារបស់កូនអ្នកនៅសាលារៀនរដ្ឋក្នុងរដ្ឋ NSW៖

### លក្ខខណ្ឌការចូលរៀន និងវគ្គសិក្សា

- កូនរបស់អ្នកត្រូវតែមករៀនយ៉ាងតិច80% នៃថ្នាក់រៀនដែលបានគ្រោងទុកទាំងអស់។ ប្រសិនបើកូនរបស់អ្នកមិនបំពេញតាមលក្ខខណ្ឌតម្រូវការចូលរៀនទេ ពួកគេអាចនឹងត្រូវបានរាយការណ៍ទៅក្រសួងកិច្ចការផ្ទៃក្នុង លុះត្រាតែអ្នកមានកាលៈទេសៈគួរឱ្យអាណិតអាសូរ ឬគួរឱ្យទុកចិត្ត (គោលការណ៍ណែនាំមានផ្តល់ជូនខាងក្រោម)។
- អ្នកត្រូវតែផ្តល់សំបុត្រពេទ្យសម្រាប់អវត្តមានរបស់កូនអ្នកដែលមានរយៈពេលបីថ្ងៃ ឬច្រើនជាងនេះ។ វេជ្ជបណ្ឌិតនោះត្រូវតែជាអ្នកអនុវត្តវេជ្ជសាស្ត្រដែលបានចុះឈ្មោះក្នុងបញ្ជីស្របច្បាប់។ ប្រសិនបើកូនរបស់អ្នកអវត្តមានមួយ ឬពីរថ្ងៃ ត្រូវផ្តល់លិខិតពន្យល់មួយច្បាប់។

### លក្ខខណ្ឌសុខុមាលភាព

- អ្នកត្រូវតែជូនដំណឹងដល់សាលារៀនកូនរបស់អ្នក អំពីអាសយដ្ឋានលំនៅដ្ឋានកូនរបស់អ្នកក្នុងរយៈពេលប្រាំពីរថ្ងៃបន្ទាប់ពីមកដល់ប្រទេសអូស្ត្រាលី ហើយជូនដំណឹងអំពីការផ្លាស់ប្តូរអាសយដ្ឋាន និងព័ត៌មានទំនាក់ទំនងណាមួយក្នុងរយៈពេលប្រាំពីរថ្ងៃ។

### លក្ខខណ្ឌនៃការចុះឈ្មោះ

- កូនរបស់អ្នកត្រូវតែចាប់ផ្តើមចូលរៀនតាមកាលបរិច្ឆេទដែលមានចុះនៅលើលិខិតបញ្ជាក់ការចុះឈ្មោះចូលរៀន ហើយប្រសិនបើមិនអាចធ្វើទៅបានទេ សូមជូនដំណឹងទៅ DE International ជាលាយលក្ខណ៍អក្សរក្នុងរយៈពេល 24ម៉ោង នៃកាលបរិច្ឆេទចាប់ផ្តើមចូលរៀនដែលមានចុះនៅលើលិខិតបញ្ជាក់ការចុះឈ្មោះចូលរៀន។
- ប្រសិនបើអ្នកជាអ្នកថែទាំដែលបានអនុម័ត អ្នកត្រូវបានតម្រូវឱ្យនៅជាមួយកូនរបស់អ្នក ខណៈពេលដែលពួកគេកំពុងចុះឈ្មោះចូលរៀននៅសាលាបឋមសិក្សា។ ប្រសិនបើអ្នកត្រូវការត្រឡប់ទៅកាន់ប្រទេសកំណើតរបស់អ្នក កូនរបស់អ្នកត្រូវតែទៅជាមួយអ្នក។
- កូនរបស់អ្នកត្រូវតែប្រកាន់ខ្ជាប់នូវវិន័យសាលា និងខថែង និងលក្ខខណ្ឌនៃការចុះឈ្មោះចូលរៀនដែលមានចែងនៅក្នុងទម្រង់ពាក្យសុំសម្រាប់និស្សិតអន្តរជាតិ។ កូនរបស់អ្នកនឹងទទួលបានព័ត៌មានអំពីវិន័យសាលា និងអាកប្បកិរិយាដែលត្រូវបានរំពឹងទុកនៅពេលចូលរួមវគ្គតម្រង់ទិស។
- សាលារៀនរបស់កូនអ្នកអាចពន្យារការសិក្សា ឬលុបចោលការចុះឈ្មោះចូលរៀនរបស់កូនអ្នក ដោយហេតុផលអាកប្បកិរិយាមិនសមរម្យ។ សម្រាប់ព័ត៌មានបន្ថែមអំពីអាកប្បកិរិយារបស់សិស្ស និងការព្យួរការសិក្សា ហើយនិងការបណ្តេញសិស្ស សូមសួរអ្នកសម្របសម្រួលនិស្សិតអន្តរជាតិរបស់អ្នកនៅសាលារៀនរបស់កូនអ្នក។
- ប្រសិនបើអ្នកចង់ផ្ទេរកូនរបស់អ្នកទៅសាលារៀនរដ្ឋមួយផ្សេងទៀត អ្នកត្រូវតែធ្វើសំណើជាលាយលក្ខណ៍អក្សរទៅកាន់សាលារៀនរបស់កូនអ្នក។
- ប្រសិនបើអ្នកចង់ផ្លាស់ប្តូរអ្នកផ្តល់សេវាកម្ម អ្នកត្រូវតែធ្វើសំណើជាលាយលក្ខណ៍អក្សរទៅកាន់សាលារៀនរបស់កូនអ្នក។
- សម្រាប់ព័ត៌មានបន្ថែមទាក់ទងនឹងបទប្បញ្ញត្តិទិដ្ឋាការអំពីការផ្លាស់ប្តូរអ្នកផ្តល់សេវាកម្ម សូមចូលទៅកាន់គេហទំព័ររបស់ក្រសួងកិច្ចការផ្ទៃក្នុង និងអ្នកសម្របសម្រួលនិស្សិតអន្តរជាតិនៅសាលារៀនរបស់កូនអ្នក។

### ការឈប់សម្រាក

- ប្រសិនបើកូនរបស់អ្នកនឹងត្រូវអវត្តមានមួយសប្តាហ៍ ឬច្រើនជាងនេះក្នុងអំឡុងត្រីមាសសិក្សា អ្នកត្រូវតែស្នើសុំការអនុម័តពីនាយកសាលា និង DE International។ អ្នកមិនត្រូវពន្យារពេលកាលបរិច្ឆេទចាប់ផ្តើមចូលរៀនរបស់កូនអ្នក ឬអនុញ្ញាតឱ្យកូនរបស់អ្នកឈប់សម្រាករយៈពេលយូរដោយគ្មានការអនុម័តពីនាយកសាលា និង DE International ឡើយ។ ការអនុម័តត្រូវបានផ្តល់តែលើហេតុផលគួរឱ្យទុកចិត្ត ឬគួរឱ្យអាណិតអាសូរប៉ុណ្ណោះ (សូមមើលគោលការណ៍ណែនាំខាងក្រោម)។

### បណ្តឹងតវ៉ា និងបណ្តឹងសាទុក្ខ

- ក្រសួងអប់រំរដ្ឋ NSW មានវិធីការនៃបណ្តឹងតវ៉ា និងបណ្តឹងសាទុក្ខ។ ប្រសិនបើអ្នកមានបំណងចង់ធ្វើបណ្តឹងតវ៉ា ឬបណ្តឹងសាទុក្ខចំពោះការសម្រេចចិត្តដែលបានធ្វើឡើងទាក់ទងនឹងការចុះឈ្មោះរបស់កូនអ្នក វឌ្ឍនភាពវគ្គសិក្សា ឬការសម្រេចចិត្តផ្សេងទៀត អ្នកគួរតែទាក់ទងអ្នកសម្របសម្រួលនិស្សិតអន្តរជាតិនៅសាលារៀនរបស់អ្នក។
- ប្រសិនបើអ្នកមិនពេញចិត្តនឹងលទ្ធផលវិធីការនៃបណ្តឹងតវ៉ា និងបណ្តឹងសាទុក្ខផ្ទៃក្នុងរបស់សាលា អ្នកនឹងត្រូវបានណែនាំអំពីរបៀបចូលប្រើប្រាស់វិធីការនៃបណ្តឹងសាទុក្ខខាងក្រៅសាលាតាមរយៈ Ombudsman NSW (អាជ្ញាធរឯករាជ្យដោះស្រាយបណ្តឹងតវ៉ាពីពលរដ្ឋក្នុងរដ្ឋ NSW)។
- កូនរបស់អ្នកត្រូវតែបន្តចុះឈ្មោះចូលរៀននៅសាលារបស់ពួកគេពេញមួយដំណើរការបណ្តឹងសាទុក្ខណាមួយ រហូតដល់ដំណើរការនេះបានបញ្ចប់។

### គោលការណ៍ណែនាំសម្រាប់កាលៈទេសៈគួរឱ្យអាណិតអាសូរ ឬគួរឱ្យទុកចិត្ត

ការឈប់សម្រាកដែលបានអនុម័តដោយហេតុផលកាលៈទេសៈគួរឱ្យអាណិតអាសូរ ឬគួរឱ្យទុកចិត្ត មិនបានរាប់បញ្ចូលក្នុងកំណត់ត្រាចូលរៀនទេ។ កាលៈទេសៈគួរឱ្យអាណិតអាសូរ ឬគួរឱ្យទុកចិត្ត ជាទូទៅគឺជាស្ថានភាពនានាដែលហួសពីការគ្រប់គ្រងរបស់អ្នក ហើយដែលមានផលប៉ះពាល់ទៅលើវឌ្ឍនភាព ឬសុខុមាលភាពរបស់កូនអ្នក។ ទាំងនេះអាចរួមបញ្ចូល ប៉ុន្តែអាចមានលើសពីនេះ៖

- ជំងឺ ដែលមានសំបុត្រពេទ្យបញ្ជាក់ថាអ្នកមិនអាចចូលរៀនបាន ឬ
- ការបាត់បង់សមាជិកគ្រួសារជិតស្និទ្ធ ដូចជាឪពុកម្តាយ ឬជីដូនជីតា (ប្រសិនបើអាចធ្វើទៅបាន គួរតែផ្តល់សំបុត្រមរណៈភាព ឬភស្តុតាងផ្សេងទៀត មុនពេលចេញដំណើរ ឬនៅពេលត្រឡប់មកវិញ) ឬ
- ចលាចលនយោបាយ ឬគ្រោះមហន្តរាយធម្មជាតិដ៏ធំនៅក្នុងប្រទេសកំណើតដែលទាមទារឱ្យពួកគេធ្វើដំណើរជាបន្ទាន់ ហើយវាមានផលប៉ះពាល់ដល់ការសិក្សារបស់អ្នក ឬ
- បទពិសោធន៍ស្លុតរន្ធត់ដែលអាចរួមបញ្ចូល ប៉ុន្តែអាចមានលើសពីនេះ៖
    - ការទាក់ទិន ឬការធ្វើជាសាក្សីនៃគ្រោះថ្នាក់មួយ
    - ការធ្វើជាសាក្សី ឬជាជនរងគ្រោះនៃឧក្រិដ្ឋកម្ម
- ហើយវាមានផលប៉ះពាល់មកលើកូនរបស់អ្នក (ករណីទាំងនេះគួរតែបានគាំទ្រដោយរបាយការណ៍របស់ប៉ូលីស ឬគ្រូពេទ្យចិត្តសាស្ត្រ ឬដំបូន្មានជាលាយលក្ខណ៍អក្សរពីអ្នកជំនាញផ្នែកវេជ្ជសាស្ត្រសមស្របម្នាក់)
- មិនអាចចាប់ផ្តើមសិក្សាតាមកាលបរិច្ឆេទនៃការចាប់ផ្តើមវគ្គសិក្សា ដោយសារតែការពន្យារពេលក្នុងការទទួលបានទិដ្ឋាការសិស្ស។